# ព្រះគម្ពីរសម្រាប់កុមារ
# សូមបង្ហាញជូន

## ព្រះរាជកំណើតនៃព្រះ
## យេស៊ូវ



និពន្ធដោយ: Edward Hughes

ធ្វើការពន្យល់ដោយ: M. Maillot

កែសម្រួលដោយ: E. Frischbutter; Sarah S.

បកប្រែដោយ: Christian Lingua

ផលិតដោយ: Bible for Children
www.M1914.org

©2018 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ អ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន ដរាបណាអ្នកមិនយកទៅលក់។

កាលពីយូរមកហើយ
ព្រះទ្រង់បានចាត់ទេវតា
កាព្រីយ៉ែលទៅឯនារីក្រមុំសាសន៍
យូដាដ៏ទន់ភ្លន់ម្នាក់
នាងនោះឈ្មោះថា ម៉ារា។



ទេវតាបានប្រាប់នាងថា
“នាងនឹងមានបុត្រា១
ហើយត្រូវថ្វាយព្រះនាមទ្រង់ថា
យេស៊ូវ។ ទ្រង់នឹងត្រូវបាន
ហៅថាជាព្រះរាជបុត្រានៃ
ព្រះដ៏ខ្ពស់បំផុត។
ទ្រង់នឹងសោ
យរាជ្យជារៀ
ងដរាបតទៅ។”



នាងក៏បានសួរទាំងក្ដីអស្ចារ្យក្នុង
ចិត្តថា “តើការនេះនឹងកើតដូច
ម្ដេចបាន បើខ្ញុំមិនដែលស្គាល់
ប្រុសណាផង?” ទេវតាក៏បាន
ប្រាប់នាងម៉ារាថា
បុត្រានោះនឹងត្រូវ
យាងមកពីព្រះ។
ទ្រង់មិនចាំបា
ច់ត្រូវការឪពុក
ជាមនុស្ស
ឡើយ។



ទេវតាបានប្រាប់នាងម៉ារាថា បងស្រី
ជីដូនមួយរបស់នាងគឺអេលីសាបែត
ក៏កំពុងតែមានគភ៌ក្នុ
ងកាលដែលមានអា
យុចាស់ហើយនោះ
ផង។ នេះក៏ជាកា
រអស្ចារ្យមួយដែរ។



ក្រោយមកមិនយូរប៉ុន្មាន
នាងម៉ារាក៏បានមកលេង
នឹងអេលីសាបែត។
ពួកគាត់បានសរ
សើរតម្កើងដល់ព្រះ
ទាំងអស់គ្នា។



នាងម៉ារាបានភ្ញាប់ពាក្យ
ជាគូដណ្ដឹងជាមួយនឹង
បុរសម្នាក់ឈ្មោះយ៉ូសែប។
លោកយ៉ូសែបមានចិ
ត្តព្រួយ ដោយគា
ត់បានដឹងថា
ម៉ារាមានគភ៌។
គាត់បានគិតថា
ប្រហែលជាឪពុក
របស់កូននោះគឺ
ជាបុរសណាម្នាក់
ផ្សេងហើយ។



នៅក្នុងការយល់សប្ត ទេវតារបស់ព្រះបាន
ប្រាប់លោកយ៉ូសែបថា បុត្រនោះ
គឺជាព្រះរាជបុត្រារបស់ព្រះ។
លោកយ៉ូសែបត្រូវធ្វើជាជំនួយដល់
នាងម៉ារាដើម្បីមើលថែព្រះយេស៊ូវ។



លោកយ៉ូសែបបានទុកចិត្ត ហើយស្ដាប់បង្គា
ប់ព្រះ។ គាត់ក៏ជាដែលស្ដាប់បង្គាប់
ច្បាប់នៅក្នុងប្រទេសរ
បស់គាត់ផ
ងដែរ។



ពីព្រោះតែច្បាប់ថ្មី ទើបគាត់ និងនាងម៉ារាត្រូវ
ចេញដំណើរទៅឯស្រុកកំណើតរបស់ពួកគាត់
គឺភូមិបេថ្លេហិម
ដើម្បីនឹងចុះប
ញ្ជីបង់ពន្ធ។




នាងម៉ារាដល់ពេល
ដែលត្រូវសម្រាលបុត្រ
ហើយ។ ប៉ុន្តែ លោក
យ៉ូសែបមិនអាចរ
កបន្ទប់ស្នាក់
នៅមួយសោះ។


គ្រប់ទាំងអស់
សំណាក់សុទ្ធតែ
ពេញអស់ហើយ។

ចុងក្រោយ លោកយ៉ូសែបរកបានក្រោលសត្វមួយ។ នៅទីនោះហើយដែលព្រះឱរសយេស៊ូវបានប្រសូតមក។




មាតាទ្រង់បានដាក់ទ្រង់នៅក្នុងស្នូកសត្វ
ដែលជាធម្មតាគឺជាកន្លែង
សម្រាប់ដាក់ចំ
ណីសត្វ។

នៅមិនឆ្ងាយពីទីនោះដែរ មានពួកអ្នកគង្វាល ដែលចាំយាមរក្សាហ្វូងចៀមរបស់ពួកគេ។



នោះទេវតានៃព្រះបានលេចមក ហើយប្រាប់
ដល់ពួកអ្នកគង្វាលអំពីដំណឹង
ល្អដ៏អស្ចារ្យមួយ។




“នៅថ្ងៃនេះ មានព្រះសង្គ្រោះ១អង្គបានប្រសូត
ដល់អ្នករាល់គ្នា នៅក្រុងហ្លួងដា
វីឌ គឺជាព្រះគ្រីស្ទជាព្រះ
អម្ចាស់។ អ្នករាល់គ្នា
នឹងឃើញ
ព្រះឱរស
ដែលកំពុងផ្ដេ
កនៅក្នុងស្នូក
សត្វមួយ។”


រំពេចនោះ ស្រាប់តែមានពួកទេវតាដ៏
ភ្លឺចែងចាំងយ៉ាងច្រើនកុះករលេ
ចមក ក៏ពោលសរសើរ
តម្កើងព្រះ
ដោយពាក្យថា
...


... “សូមថ្វាយសិរីល្អដល់ព្រះនៅស្ថានដ៏ខ្ពស់
បំផុត ហើយសូមឲ្យសេចក្ដីសុខ
សាន្តមាននៅផែនដី
នៅកណ្ដាល
មនុស្ស
ដែលជាទីគាប់ព្រះ
ហឫទ័យដល់ទ្រង់។”

ពួកអ្នកគង្វាលក៏ប្រញាប់
ទៅឯក្រោយសត្វ។




ក្រោយដែលបានឃើញព្រះឱរសហើយ
នោះពួកគេក៏បានដំណាលប្រាប់ដល់មនុស្ស
គ្រប់គ្នាទាំងឡាយណាដែលពួកគេបានជួប
អំពីការដែលពួកទេវតាបានថ្លែងប្រាប់រឿង
ព្រះយេស៊ូវនោះ។



សែសិបថ្ងៃក្រោយមក យ៉ូសែ
ប និងនាងម៉ារាបាននាំព្រះ
យេស៊ូវទៅឯព្រះវិហារនៅ
ក្រុងយេស៊ូវសាឡិម។
មានបុរសម្នាក់ឈ្មោះ
ស៊ីម្មានបានសរសើរ
ដល់ព្រះដោយព្រះបា
នឃើញព្រះឱរស
រីឯនាងអាណ
ដែលជាស្ត្រីវ័យចំ
ណាស់ម្នាក់ ...



... និងជាអ្នកបម្រើដល់ព្រះ
ផង នាងក៏ថ្លែងអរព្រះ
គុណដល់ព្រះដែរ។
អ្នកទាំងពីរសុទ្ធតែ
ដឹងថា ព្រះយេស៊ូវគឺ
ជាព្រះរាជបុត្រានៃ
ព្រះ គឺជាព្រះអង្គ
សង្គ្រោះដែលបា
នសន្យាថានឹង
ត្រូវយាងមក។



លោកយ៉ូសែបបានថ្វាយសត្វ
ស្លាបពីរចំពោះព្រះ។
នេះគឺជាគឺជាដង្វាយ
ដែលក្នុងក្រឹត្យវិន័យ
របស់ព្រះបានតម្រូវ
សម្រាប់អ្នកក្រីក្រ
ដែលត្រូវថ្វាយចំ
ពោះព្រះនៅពេលពួ
កគេយកកូនប្រុស
ជាចម្បងមកថ្វាយ
ដល់ព្រះអម្ចាស់។



វេលាក្រោយមក
ទៀត មានផ្កាយ
ដ៏ពិសេសមួយបា
ននាំផ្លូវពួក

អ្នកប្រាជ្ញមកពីទិសខាងកើត
ឲ្យធ្វើដំណើរមកដល់ទីក្រុង
យេរូសាឡិម។



ពួកលោកបាន
សួរថា “តើបុត្រា
ដែលត្រូវប្រសូត
មកធ្វើជា
ស្តេច
នៃសាសន៍យូដានៅឯណា?
ពួកយើងខ្ញុំចង់ក្រាប
ថ្វាយបង្គំទ្រង់។”

ស្ដេចហេរ៉ូឌបានឮអំពី
ពួកអ្នកប្រាជ្ញនោះ។
ដោយមានព្រះទ័យត
ក់ស្លុតផង ទ្រង់ក៏បាន
សុំឲ្យពួកអ្នកប្រាជ្ញទាំង
នោះប្រាប់ដល់ទ្រង់វិញ
ផង នៅពេលដែលពួក
លោករកឃើញព្រះ
យេស៊ូវ។



ទ្រង់មានបន្ទូលថា
“យើងចង់ថ្វាយបង្គំ
ទ្រង់ដែរ។” ប៉ុន្តែ
ទ្រង់កុហកទេ។
គឺស្តេចហេរ៉ូឌចង់
ធ្វើគុតព្រះយេស៊ូវ
ទៅវិញទេ។



ផ្កាយនោះបាននាំពួកអ្នកប្រាជ្ញ
ទៅដល់ចំផ្ទះមួយដែលនាងម៉ារា
និងយ៉ូសែប
កំពុងរស់នៅជាមួយនឹ
ងព្រះកុមារយេស៊ូវ។



ពួកលោកក៏លុតជង្គង់ចុះ ហើយ
ថ្វាយបង្គំ ព្រមទាំងបានថ្វាយព្រះ
យេស៊ូវនូវដង្វាយជាមាស់
និងកំញ្ញានដ៏ច្រើនទៀ
តផង។



ព្រះទ្រង់បានព្រមានដល់
ពួកអ្នកប្រាជ្ញទាំងនោះឲ
្យវិលត្រឡប់ទៅស្រុក
របស់ពួកគាត់វិញដោយ
សម្ងាត់។




ស្ដេចហេរ៉ូឌក៏មានសេចក្ដី
ក្រោធយ៉ាងខ្លាំង។
ហេតុតែចង់ ...


... បំផ្លាញព្រះយេស៊ូ
វចោល ស្តេចអាក្រក់នោះ
ក៏បញ្ជាឲ្យសម្លាប់ក្មេងប្រុ
សៗនៅបេថ្លេហិមចោល
ទាំងអស់។



ប៉ុន្តែ ហេរ៉ូឌមិនបាន
បង្កការគ្រោះថ្នាក់ដល់
ព្រះរាជបុត្រានៃព្រះ
បានឡើយ!



ដោយទទួលបានការ
ព្រមានជាមុននៅក្នុង
ការពន្យល់សប្ត នោះយ៉ូ
សែបក៏បាននាំនាងម៉ារា
និងព្រះយេស៊ូវគេច
ខ្លួនទៅឯស្រុកអេស៊ី
ព្ទដោយសុវត្ថិភាព។

ពេលស្តេចហេរ៉ូឌ
សោយទិវង្គតហើយ



ទើបយ៉ូសែបបាននាំនាងម៉ារា
និងព្រះយេស៊ូវត្រឡប់ពីស្រុកអេស៊ីព្ទវិញ។



ពួកគាត់ក៏មករស់
នៅក្នុងភូមិតូចមួយឈ្មោះ
ណាសារ៉ែត នៅជិតនឹងសមុទ្រកាលីឡេ។

ព្រះរាជកំណើតនៃព្រះយេស៊ូវ

រឿងមួយដែលបានមកពីព្រះបន្ទូលរបស់ព្រះ
គឺជាព្រះគម្ពីរ

អាចរកឃើញនៅក្នុង

ម៉ាថាយ ១-២; លូកា ១-២

“ការបើកសំដែងព្រះបន្ទូលទ្រង់
នោះផ្សាយពន្លឺចេញ។” ទំនុកដំកើង ១១៩:១៣០

ថប់

រឿងព្រះគម្ពីរនេះប្រាប់យើងអំពីព្រះដ៏អស្ចារ្យរបស់យើង
ដែលបានបង្កើតយើង
ហើយដែលសព្វព្រះទ័យឲ្យអ្នកស្គាល់ដល់ទ្រង់។

ព្រះអង្គជ្រាបថាយើងបានប្រព្រឹត្តអំពើអាក្រក់
ដែលទ្រង់ហៅថាជាអំពើបាប។
ទោសនៃអំពើបាបគឺជាសេចក្តីស្លាប់
ប៉ុន្តែព្រះទ្រង់ស្រឡាញ់អ្នកខ្លាំងណាស់
ទើបទ្រង់បានចាត់ព្រះរាជបុត្រាទ្រង់តែ១ ព្រះនាមថាព្រះយេស៊ូវ
ឲ្យមកសុគតនៅលើឈើឆ្កាង ហើយឲ្យរងទោសជំនួសអំពើបាបរបស់អ្ន
ក។ បន្ទាប់មក ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញ
រួចទ្រង់យាងទៅស្ថានសួគ៌វិញ! ប្រសិនបើអ្នកជឿព្រះយេស៊ូវ
ហើយទូលសូមទ្រង់ឲ្យអភ័យទោសអំពើបាបរបស់អ្នក
នោះទ្រង់នឹងអត់ទោសឲ្យជាពិត! ទ្រង់ក៏នឹងយាងមក
ព្រមទាំងគង់នៅក្នុងជីវិតរបស់អ្នកឥឡូវ
ហើយអ្នកនឹងបានរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿចំពោះសេចក្តីពិតនេះ
នោះចូរទូលសេចក្តីនេះដល់ព្រះអង្គថា៖
ព្រះយេស៊ូវអើយ ខ្ញុំជឿថាទ្រង់គឺជាព្រះ
ដែលបានយាងមកកើតជាមនុស្សដើម្បីសុគតជំនួយអំពើបាបរបស់ខ្ញុំ
ហើយទ្រង់ក៏មានព្រះជន្មរស់ឡើងវិញរហូតដល់សព្វថ្ងៃ។
សូមយាងមកគង់ក្នុងជីវិតរបស់ខ្ញុំ
ហើយសូមអភ័យទោសអំពើបាបរបស់ខ្ញុំ
ដើម្បីឲ្យខ្ញុំមានជីវិតថ្មីនាពេលឥឡូវនេះ
រហូតដល់ថ្ងៃដល់ដែលខ្ញុំអាចទៅនៅជាមួយទ្រង់ជារៀងរហូត។
សូមជួយខ្ញុំឲ្យចេះស្តាប់បង្គាប់ទ្រង់
ហើយរស់នៅសម្រាប់ទ្រង់ក្នុងនាមជាកូនរបស់ព្រះអង្គផង។
អាម៉ែន។

សូមអានព្រះគម្ពីរ ហើយសន្ទនាជាមួយព្រះរាល់ថ្ងៃ!
យ៉ូហាន ៣:១៦